សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# កិច្ចសន្យាប្រៀនធាយនៅក្រុមហ៊ុន ជីភីហ្សាខមផេនី
# ( The Pizza Company )

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ក. សាំង ស៊ីវលិញ**

សាស្ត្រាចារ្យណែនាំ
លោក **ជិន វណ្ណារ៉ា**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី១៥

ឆ្នាំចូលសិក្សា ២០១១
ឆ្នាំសរសេរសារណា ២០១៥

# **សេចក្តីថ្លែងអំណរគុណ**

នាងខ្ញុំ **សាំង ស៊ីវលិញ** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី១៥ ក្រុម$L_{៥}C_{៥}$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចុះមកធ្វើកម្មសិក្សាលើប្រធានបទ"**កិច្ចសន្យាហ្វ្រេនឆាយ**" ដើម្បីធ្វើជាសារណាបញ្ចប់ការសិក្សាឆ្នាំ២០១៤-២០១៥។

សូមក្រាបប្រណិប័តន៍ ថ្លែងអំណរគុណដោយក្តីកត្តញ្ញូតាធម៌ និងដោយក្តីគោរពដ៏ខ្ពង់ខ្ពស់ដល់លោកឪពុក **តាន់ សាំង** អ្នកម្តាយ **អ៊ឹង គារ** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាប្រៀនប្រដៅដល់រូបកូន។

នាងខ្ញុំ សូមថ្លែងអំណរគុណផងដែរ ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោកសាស្ត្រាចារ្យ** បុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេសរដ្ឋាភិបាល ក៏ដូចជាធនាគារពិភពលោកដែលបានសហការផ្តល់អាហារូបករណ៍ដល់រូបនាងខ្ញុំ និងបុគ្គលិកនៅគ្រឹះស្ថានឧត្តមសិក្សាដែលទទួលបន្ទុកគ្រប់គ្រងនិស្សិតអាហារូបករណ៍ដែលជាអ្នកមានគុណទី២របស់នាងខ្ញុំ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត ក្នុងការរៀបចំបង្ហាត់បង្រៀន ណែនាំទាំងចំណេះដឹង ចំណេះធ្វើយ៉ាងជ្រាលជ្រៅ និងមានតំលៃសម្រាប់អានាគត់ដ៏រុងរឿងមកដល់នាងខ្ញុំ។

ជាពិសេសសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **ជិន វណ្ណារ៉ា** ដែលបានផ្តល់ប្រឹក្សាណែនាំយោបល់ លើកទឹកចិត្ត និងចំណាយពេលវេលាដ៏មានតំលៃដើម្បីជួយដឹកនាំដល់រូបនាងខ្ញុំតាំងពីចាប់ផ្តើមរហូតដល់បញ្ចប់ការសិក្សាស្រាវជ្រាវ។

សូមថ្លែងអំណរគុណចំពោះលោកនាយក និងបុគ្គលិកគ្រប់រូបនៃក្រុមហ៊ុន EFG(Express Food Group)Co .,Ltd ដែលជាក្រុមហ៊ុនធំគ្រប់គ្រងលើក្រុមហ៊ុន **ដឹភីហ្សាខមផៃនី** (The Pizza Company) ដែលបានអនុញ្ញាតឲ្យនាងខ្ញុំបានចុះកម្មសិក្សា ថែមទាំងបានចំណាយពេលវេលាដ៏មានតំលៃរបស់ខ្លួនដែលមានតំលៃដល់រូបនាងខ្ញុំក្នុងការសាកសួរព័ត៌មាន និងផ្តល់ជាឯកសារមួយចំនួន ថែមទាំងជួយពន្យល់ណែនាំយ៉ាងយកចិត្តទុកដាក់បំផុត និងជាពិសេសគឺបុគ្គលិកគ្រប់ផ្នែកទាំងអស់ដែលបានស្វាគមន៍យ៉ាងពេញចិត្តដល់រូបនាងខ្ញុំ។

ជាទីបញ្ចប់នេះ នាងខ្ញុំសូមជូនពរបវរសួស្តី សិរីមង្គលចំពោះលោកអ្នកមានគុណទាំងអស់គ្នា សូមជួបប្រទះតែសេចក្តីសុខ ចំរើនរុងរឿង សំណាងល្អ និងទទួលបានជោគជ័យគ្រប់ពេលវេលារាល់ភារកិច្ចទាំងអស់ ព្រមទាំងសូមជូនពរដល់ក្រុមហ៊ុន The Pizza Company សូមឲ្យមានដំណើរការល្អ មានការរីកចំរើនទៅមុខឥតឈប់ឈរជារៀងរហូតតទៅ។

# អារម្ភកថា

ឆ្លងតាមរយៈការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំកន្លងមក ធ្វើឲ្យនាងខ្ញុំទទួលបាននូវចំណេះដឹងថ្មីៗ និងល្អៗជាច្រើន។ ជាងនេះទៅទៀតនៅចុងឆ្នាំទី៤នេះផងដែរ សាកលវិទ្យាល័យ ក៏មានផ្តល់ឱកាសដល់រូបនាងខ្ញុំ ក្នុងការចុះសិក្សាស្រាវជ្រាវនូវសារណាសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផងដែរ។ ប្រធានបទនៃសារណាមួយនេះ ផ្តើមចេញពីទស្សនៈនៃការយល់ឃើញរបស់នាងខ្ញុំ ទៅលើវិស័យនីតិពាណិជ្ជកម្មនៅកម្ពុជា។ នាងខ្ញុំសង្កេតឃើញថា វិស័យក្រុមហ៊ុន (វិស័យពាណិជ្ជកម្ម) គឺជាវិស័យដ៏ចំបងមួយ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ជាធម្មតានៅក្នុងការប្រកបអាជីវកម្ម ការធ្វើជំនួញរបស់ពាណិជ្ជករ ការធ្វើពាណិជ្ជកិច្ច រវាងក្រុមហ៊ុននីមួយៗតែងតែជួបប្រទះ និងការចរចាការព្រមព្រៀង និងឈានទៅដល់ការបង្កើតកិច្ចសន្យា ជាពិសេសកិច្ចសន្យាក្រុមហ៊ុន ដែលទាក់ទងទៅនឹងក្រុមហ៊ុនបរទេសមួយចំនួនហៅថា **"កិច្ចសន្យាហ្វ្រេនឆាយ"** ដែលជាចំនុចដ៏សំខាន់សម្រាប់ទំនាក់ទំនងក្រុមហ៊ុនពាណិជ្ជកម្ម លើវិស័យសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអានាគត់។ ហេតុនេះហើយ បានជាកិច្ចសន្យាហ្វ្រេនឆាយមានតួនាទីសំខាន់ និងបានរីកចំរើននូវប្រភពប្រត្តិបត្តការអាជីវកម្មទាំងធនតូច ធំ និងធនមធ្យមជាច្រើនប្រភេទសម្រាប់ជាជម្រើស និងការបំពេញតំរូវការទៅកាន់អតិថិជន និងធ្វើឲ្យប្រទេសជាតិកាន់តែរីកចំរើនមួយកំរិតលើវិស័យសេដ្ឋកិច្ច ជាពិសេសគឺនីតិវិធីនៃការសុំសិទ្ធិប្រកបអាជីវកម្ម ការផ្ទេរ ការផ្អាក និងសំណងវិបត្តិផ្សេងៗដែលកើតចេញពីកិច្ចសន្យាហ្វ្រេនឆាយ។ នាងខ្ញុំសង្ឃឹមថា កិច្ចការស្រាវជ្រាវនេះ មិនត្រឹមតែបានផ្តល់ជាឯកសារជំនួយបន្ថែមដល់នាងខ្ញុំផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចផ្តល់នូវឯកសារជំនួយ ដល់អ្នកដទៃទៀតដែលមានបំណងចង់ស្វែងយល់បន្ថែមពីខ្លឹមសារ និងនីតិវិធីផ្សេងៗដែលពាក់ព័ន្ធ និងកិច្ចសន្យាហ្វ្រេនឆាយទាក់ទងទៅនឹងកិច្ចសន្យាហ្វ្រេនឆាយរបស់ក្រុមហ៊ុន The Pizza Company។

ដោយយោង ទៅតាមរយៈពេលនៃការសិក្សាស្រាវជ្រាវមានកម្រិត វាជាហេតុធ្វើឲ្យសារណាបញ្ចប់ការសិក្សានេះមិនមានលក្ខណៈលំអិត ពោលគឺត្រូវបានលើកឡើងតែចំណុចសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងប្រធានបទតែប៉ុណ្ណោះ។ ទោះបីជានាងខ្ញុំខិតខំប្រឹងប្រែងក្នុងការសរសេរ និងធ្វើការកែតំរូវជាច្រើនលើកច្រើនសារយ៉ាងណាក៏ដោយ ក៏នៅមិនអាចជៀសផុត ពីចំណុចខ្វះខាតបានឡើយ ទាំងផ្នែកអត្ថន័យ ខ្លឹមសារ និងអក្ខរាវិរុទ្ធ។ អាស្រ័យហេតុនេះហើយ នាងខ្ញុំសូមអភ័យទោសទុកជាមុនពីសំណាក់លោកអគ្គនាយក លោក-លោកស្រីសាស្ត្រាចារ្យ អស់លោក-លោកស្រីព្រមទាំងមិត្តអ្នកអាន និងមិត្តនិស្សិតទាំងអស់ ហើយនាងខ្ញុំរង់ចាំទទួលដោយក្តីរីករាយនូវការរិះគន់ក្នុងន័យស្ថាបនាដើម្បីឲ្យកិច្ចការស្រាវជ្រាវនេះកាន់តែមានភាពប្រសើរឡើង។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................................................................................១

## ជំពូកទី១
## អំពីក្រុមហ៊ុនជីភីហ្សាខមផេនី

១.១. ប្រវត្តិនៃការករកើតក្រុមហ៊ុនជីភីហ្សាខមផេនី ............................................................៤

១.១.១. រចនាសម្ព័ន្ធនៃក្រុមហ៊ុនជីភីហ្សាខមផេនី.................................................................៤

១.១.២. ទីតាំង និងសាខា ....................................................................................................៥

១.១.៣. ប្រភេទរស់ជាតិ និងសំបកភីហ្សា .............................................................................៥

១.២. គុណសម្បត្តិ និងគុណវិបត្តិ.......................................................................................៦

១.២.១. គុណសម្បត្តិ...........................................................................................................៦

១.២.២. គុណវិបត្តិ..............................................................................................................៨

## ជំពូកទី២
## ការបង្កើតកិច្ចសន្យាប្រេនឆាយ

២.១. លក្ខណៈទូទៅនៃកិច្ចសន្យា ........................................................................................ ៩

២.១.១. លក្ខខណ្ឌទូទៅនៃកិច្ចសន្យា ................................................................................១០

២.១.២. ការព្រមព្រៀង.......................................................................................................១២

២.១.៣. សមត្ថភាព............................................................................................................ ១៣

២.១.៤. កម្មវត្ថុ................................................................................................................ ១៥

២.១.៥. មូលហេតុ.............................................................................................................. ១៦

២.២. លក្ខខណ្ឌពិសេសនៃកិច្ចសន្យាប្រេនឆាយ..................................................................... ១៧

២.២.១. ការស្វែងរកអ្នកទទួលប្រេនឆាយ............................................................................ ១៧

២.២.២. កិច្ចសន្យាបឋម .....................................................................................................១៨

២.២.៣. លក្ខខណ្ឌអប្បបរមាសំខាន់ៗ.......................................................២០
២.២.៤. លក្ខខណ្ឌសុពលភាព ....................................................................... ២២
២.២.៥. លក្ខខណ្ឌតតាំងតតិយជន.................................................................. ២២
២.២.៦. រយៈពេលនៃកិច្ចសន្យា.....................................................................២៣

## ជំពូកទី៣
## អានុភាពនៃកិច្ចសន្យាប្រៀនឆាយ

៣.១. កិច្ចសន្យាប្រៀនឆាយបង្កើតសិទ្ធិជាបច្ច័យ......................................................២៤
៣.១.១. សិទ្ធិរបស់ម្ចាស់ប្រៀនឆាយ...................................................................២៤
៣.១.២. សិទ្ធិរបស់អ្នកទទួលប្រៀនឆាយ...........................................................២៥
៣.២. កិច្ចសន្យាប្រៀនឆាយបង្កើតជាកាតព្វកិច្ច.........................................................២៦
៣.២.១. កាតព្វកិច្ចម្ចាស់ប្រៀនឆាយ...................................................................២៦
៣.២.២. កាតព្វកិច្ចអ្នកទទួលប្រៀនឆាយ ..........................................................២៧

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន..........................................................................................២៨
២. អនុសាសន៍ ................................................................................................ ៣១

**ឧបសម្ព័ន្ធ**
**ឯកសារយោង**

# សេចក្តីផ្តើម

ប្រទេសកម្ពុជាសព្វថ្ងៃ កាន់តែបោះជំហ៊ានមានសន្ទុះផ្នែកអាជីវកម្ម ជាពិសេសក្នុងវិស័យពាណិជ្ជកម្ម។ ជាការពិតណាស់ប្រទេសកម្ពុជា បានក្លាយជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤[១]។ ការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ពិតជាមានការផ្តល់អត្ថប្រយោជន៍ និងបញ្ហាប្រឈមខ្លះៗផងដែរ។ ការទទួលបានអត្ថប្រយោជន៍មានដូចជា ការទាក់ទាញអ្នកវិនិយោគិនមកបណ្តាក់ទុនកាន់តែច្រើន ព្រមទាំងជាការផ្តល់ទំនុកចិត្តធ្វើឲ្យអ្នកវិនិយោគិន មានភាពជឿជាក់ក្នុងទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងបណ្តារប្រទេសនានាលើសាកលលោក។ ម្យ៉ាងទៀតប្រទេសកម្ពុជាបានគេចផុតពីភាពឯកោតែម្នាក់ឯងហើយ។ ក៏ប៉ុន្តែវាពិតជាមានបញ្ហាប្រឈមខ្លះៗដូចជា កង្វះធនធានមនុស្ស កង្វះនូវបទដ្ឋានគតិយុត្តដែលមានសុខដុមរមនីយកម្ម (Harmonization) ព្រមទាំងការគោរពនូវកម្មសិទ្ធិបញ្ញា។ ស្ថាប័នគ្រប់គ្រងផ្នែកអាជីវកម្ម ដែលមានលក្ខណៈសាកលនៅលើពិភពលោកគឺ អង្គការពាណិជ្ជកម្មពិភពលោក (WTO) ដោយយោងតាមរបាយការណ៍ទិន្នន័យចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៥ អង្គការពាណិជ្ជកម្មពិភពលោកត្រូវបានបង្កើតឡើងនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៥ ក្រោយកំឡុងពេលចរចារ នៅចន្លោះឆ្នាំ១៩៨៦ ទៅឆ្នាំ១៩៩៤ ដែលមានសមាជិកសរុបចំនួន១៦១ប្រទេស ហើយមានទីតាំងនៅទីក្រុង Geneva ប្រទេស Switzerland ដែលមានលោក Roberto Azeve´do ជាប្រធាន។ ដូចនេះប្រទេសកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ដែលមានចែងនៅមាត្រា១ ក្នុងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកស្តីពី ការអនុម័តយល់ព្រមលើពិធីសារ ដែលបានចុះហត្ថលេខានៅទីក្រុង**គែន គុន** ប្រទេស**ម៉ិចស៊ិច** កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ហើយត្រូវបានព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់គតិច្បាប់ទាំងស្រុងនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៤[២]។ ហើយកម្ពុជាក៏ចូលជាសមាជិកនៃសមាហារណកម្មនៃសហគមន៍អាស៊ាននាពេលថ្មីៗនេះ ដែលធ្វើឲ្យប្រទេសកម្ពុជា មានភាពរីកចំរើនខាងវិស័យពាណិជ្ជកម្មគួរឲ្យកត់សម្គាល់។ លំហូនៃអ្នកវិនិយោគិនជាច្រើន បានកើនឡើងក្នុងការចូលមកវិនិយោគនៅប្រទេសកម្ពុជា។ តួយ៉ាងការបើកចំហរវិស័យសមាហារណពាណិជ្ជម្មនេះ យើងសង្កេតឃើញថា មានការអនុវត្តន៍តាមលំនាំបរទេសផងដែរ។ ដោយសារ តែសាកលភាវូបនីយកម្មពាណិជ្ជកម្មអន្តរជាតិ យើងឃើញមានសកម្មភាពពាណិជ្ជកម្មមួយបែប ដែលធ្វើការអនុវត្តដែលពាក់ព័ន្ធទៅនឹង ការទិញសិទ្ធិសុំប្រើប្រាស់

[១] https://www.wto.org/english/thewto_e/what_are_e.htm ចូលមើលថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥

[២] រាជកិច្ចចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤, (ទំព័រ២០៤៨-ទំព័រ២០៤៩)

កម្មសិទ្ធិទៅលើម៉ាកពាណិជ្ជនាម ហើយអាចទាញយកការប្រើប្រាស់នូវកម្មសិទ្ធិបញ្ញានោះ យកទៅធ្វើពាណិជ្ជកិច្ចរបស់ខ្លួនបាន ការធ្វើពាណិជ្ជកិច្ចដែលមានលំនាំដូចរៀបរាប់ខាងលើ គេហៅថាជាប្រភេទនៃ "**កិច្ចសន្យាហ្វ្រេនឆាយ**" កិច្ចសន្យាហ្វ្រេនឆាយមិនមែនជាសញ្ញាណដំបូង សំរាប់ប្រទេសកម្ពុជានោះទេ ជាក់ស្តែងការបង្កើតហ្វ្រេនឆាយ ធ្លាប់ឃើញមានច្រើនកន្លងរួចមកហើយ តាមរយៈការអនុវត្តដូចជា ការ៉េម Swensen's Costa Coffee KFC និងភេសជ្ជៈ**កូកាកូឡា**ជាដើម។ ហើយប្រទេសកម្ពុជា ក៏ពុំទាន់មាន ច្បាប់ស្តីពីទំនាក់ទំនងហ្វ្រេនឆាយជាក់លាក់នៅឡើយទេ ព្រោះថាហ្វ្រេនឆាយកើតដំបូង នៅសហរដ្ឋអាមេរិកប្រមាណជា២សតវត្សរ៍ និងបានសាយភាយមកប្រទេសកម្ពុជាយើង ក្នុងកំឡុងពេលជា៥ឆ្នាំចុងក្រោយនេះតែប៉ុណ្ណោះ។

ហើយទើបតែនៅឆ្នាំ២០១១ ទើបកម្ពុជាបានបង្កើតសេចក្តីព្រាងស្តីពី "**កិច្ចសន្យាពាណិជ្ជកម្ម**" ដែលមានចែងពីការគ្រប់គ្រងស្តីពីកិច្ចសន្យាហ្វ្រេនឆាយនេះនៅផ្នែកទី៥។ ដោយសារតែថា កម្ពុជាទើបតែមានសកម្មភាពអនុវត្តហ្វ្រេនឆាយគួរឲ្យកត់សម្គាល់។ លើសពីនេះទៅទៀត នៅពេលដែលប្រទេសកម្ពុជា គ្រាន់តែមានសេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ស្របពេលដែលហ្វ្រេនឆាយមានការអនុវត្តយូរហើយ ដែលជាចំនុចដែលនាំឲ្យនាងខ្ញុំជ្រើសយកប្រធានបទ "**កិច្ចសន្យាហ្វ្រេនឆាយ**" ដែលទាក់ទងទៅនឹង **ក្រុមហ៊ុនដឹភីហ្សាខមផេនី** The Pizza Company ដែលជាក្រុមហ៊ុនអនុវត្តកិច្ចសន្យាហ្វ្រេនឆាយ ហើយកំពុងតែមានឈ្មោះបោះសំលេង នៅប្រទេសកម្ពុជាមកធ្វើជាប្រធានបទស្រាវជ្រាវតែម្តង។

ប្រធានបទខាងលើ នឹងធ្វើការឆ្លើយតបទៅនឹងសំណួរដូចជា៖ តើកិច្ចសន្យាហ្វ្រេនឆាយមានកំណត់នូវលក្ខខណ្ឌនៃការបង្កើត និងត្រូវមានការទទួលខុសត្រូវដែលបង្កើតជាសិទ្ធិ និងកាតព្វកិច្ចដូចម្តេចខ្លះ?

ដើម្បីបំភ្លឺ នូវសំណួរដែលបានចោទខាងលើ នាងខ្ញុំសូមទាញនូវសម្មិតិកម្មពាណិជ្ជកម្មបានថា កិច្ចសន្យាហ្វ្រេនឆាយ ដែលបានដកស្រង់ចេញពីសេចក្តីព្រាងស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ត្រូវបានកំណត់លក្ខខណ្ឌចងជាសិទ្ធិ និងកាតព្វកិច្ចចំពោះភាគីនីមួយៗនៃកិច្ចសន្យាហ្វ្រេនឆាយ យ៉ាងច្បាស់លាស់។

កិច្ចការស្រាវជ្រាវនេះ មានគោលបំណងចំបងៗដែលមានដូចជា តើគូភាគីនៃកិច្ចសន្យាហ្វ្រេនឆាយត្រូវបង្កើតឡើងឆ្លងកាត់នូវលក្ខខណ្ឌអ្វីខ្លះ? តើភាគីនៃកិច្ចសន្យាហ្វ្រេនឆាយមានសិទ្ធិ និងកាតព្វកិច្ចដូចម្តេចខ្លះ? តើមាននីតិវិធីដូចម្តេចខ្លះក្នុងការសុំសិទ្ធិប្រកបអាជីវកម្មដែលទាក់ទងទៅនឹងកិច្ចសន្យាហ្វ្រេនឆាយ? តើការបង្កើតកិច្ចសន្យាហ្វ្រេនឆាយនៅប្រទេសកម្ពុជា ត្រូវបង់ពន្ធជូនរដ្ឋ

ប៉ុន្មានភាគរយ? តើកិច្ចសន្យាហ្វ្រេនឆាយបានបង្កើតជាគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះដល់សេដ្ឋកិច្ចប្រទេសកម្ពុជា?

គោលបំណងនៃកិច្ចការស្រាវជ្រាវមួយនេះ គឺនាងខ្ញុំចង់បង្ហាញ ឲ្យកាន់តែលម្អិតនូវកិច្ចសន្យាហ្វ្រេនឆាយដែលជាទូទៅប្រជាពលរដ្ឋកម្ពុជាយើង មិនសូវជាស្គាល់ថា អ្វីទៅជាកិច្ចសន្យាហ្វ្រេនឆាយ តើកិច្ចសន្យានេះ មានប្រភពដើមពីប្រទេសណា។ ម្យ៉ាងវិញទៀត ចំពោះប្រភពឯកសារចងក្រងស្រាវជ្រាវភាគច្រើន មានតែជាភាសាបរទេស និងនាងខ្ញុំសង្កេតឃើញថា នៅតាមបណ្ណាល័យផ្សេងៗមានភាពពិបាក ក្នុងការស្វែងរកឯកសារដែលទាក់ទងទៅនឹងកិច្ចសន្យាហ្វ្រេនឆាយ ជាភាសាខ្មែរណាស់ ហើយប្រសិនបើមានក៏មិនសូវបានលម្អិត និងមានច្រើនទេ ហើយចំនួនដែលត្រូវបានធ្វើបច្ចុប្បន្នភាពស្រាវជ្រាវតិចតួចណាស់។ ជាតួយ៉ាងយើងឃើញមាន ក្រុមហ៊ុនជាច្រើន ដែលបានយកលំនាំអនុវត្តតាមកិច្ចសន្យាហ្វ្រេនឆាយ និងទទួលបានជោគជ័យនៅក្នុងអាជីវកម្មរបស់ខ្លួន។ នេះគឺជាអ្វីដែលបានកើតឡើងនៅប្រទេសកម្ពុជាគួរឲ្យកត់សម្គាល់ ប៉ុន្តែឯកសារស្រាវជ្រាវដែលទាក់ទងទៅនឹងកិច្ចសន្យាឆាយនៅតែមានចំនួនស្តួចស្តើងនៅឡើយ។ ដូចនេះ នាងខ្ញុំសង្ឃឹមថាកិច្ចស្រាវជ្រាវនេះនឹងជួយបង្កើនចំនួនឯកសារស្រាវជ្រាវ ស្តីពីកិច្ចសន្យាហ្វ្រេនឆាយបានមួយកម្រិត នៅក្នុងគោលបំណងចង់ទទួលចំណេះដឹងថ្មីៗ និងសម្រាប់ជាឯកសារជំនួយបន្ថែម ទៅដល់សិស្សនិស្សិតជំនាន់ក្រោយ ធ្វើការស្រាវជ្រាវ និងបន្តធ្វើបច្ចុប្បន្នភាព លើការអនុវត្តតាមលំនាំហ្វ្រេនឆាយនៅប្រទេសកម្ពុជា។

ប្រធានបទកិច្ចការស្រាវជ្រាវនេះ នឹងរៀបរាប់ផ្សារភ្ជាប់ និងពាក់ព័ន្ធយ៉ាងជិតស្និតជាមួយនឹងកិច្ចសន្យាពាណិជ្ជកម្មដែលធ្វើនៅប្រទេសកម្ពុជា ហើយពាក់ព័ន្ធទៅនឹងកិច្ចសន្យាជាមួយប្រទេសដទៃ។

នាងខ្ញុំបាន ស្វះស្វែងរកឯកសារមកធ្វើជាមូលដ្ឋាននៃកិច្ចការស្រាវជ្រាវទាំងមូលនេះ ដែលបានដកស្រង់ចេញពី ក្រមរដ្ឋប្បវេណី សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១ សេចក្តីព្រាងស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ដែលទាក់ទងនឹងកិច្ចសន្យាហ្វ្រេនឆាយ និងការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណេតជាភាសាបរទេសមួយចំនួន ព្រមទាំងកិច្ចសន្យាហ្វ្រេនឆាយចេញពី **ក្រុមហ៊ុនដឹភីហ្សាខមផេនី The Pizza Company** ដែលបានមកពីការជួបផ្ទាល់តាមរយៈការសំភាសន៍បន្ថែមទៀត។

ជាលទ្ធផលនៃការស្រាវជ្រាវរបស់នាងខ្ញុំ ធ្វើឲ្យនាងខ្ញុំកាន់តែមានចំណេះដឹង កាន់តែច្បាស់ទាក់ទងទៅនឹងកិច្ចសន្យាហ្វ្រេនឆាយបន្ថែមទៀតផងដែរ។

# ជំពូកទី១

# អំពីក្រុមហ៊ុនដឺភីហ្សាខមផេនី

## ១.១. ប្រវត្តិករកើតនៃក្រុមហ៊ុនដឺភីហ្សាខមផេនី

**ក្រុមហ៊ុនដឺភីហ្សាខមផេនី** (The Pizza Company) បានទទួលប្រេ្វនឆាយពី **ក្រុមហ៊ុនម៉ាញន័រហ្វូតគ្រុប** (Minor Food Group) ពីប្រទេសថៃដែលបានបំរើសេវាកម្មម្ហូបអុីតាលី និងគ្រឿងផ្សំរបស់សហរដ្ឋអាមេរិកដោយផ្តោតលើផលិតផលភីហ្សា ដែលបានអនុវត្តដំបូង នៅទីតាំងផ្សារទំនើបសុរិយា នៃប្រទេសកម្ពុជានៅក្នុងឆ្នាំ២០០៥។

### ១.១.១. រចនាសម្ព័ន្ធនៃក្រុមហ៊ុនដឺភីហ្សាខមផេនី

ដោយនាងខ្ញុំបានលើកយក **ក្រុមហ៊ុនដឺភីហ្សាខមផេនី** មកធ្វើជាគោលក្នុងការសិក្សាពីស្ថានភាពជាក់ស្តែងរបស់ក្រុមហ៊ុន ដែលអនុវត្តតាមលំនាំកិច្ចសន្យាប្រេ្វនឆាយ ហើយនាងខ្ញុំសង្កេតឃើញថា **ក្រុមហ៊ុនដឺភីហ្សាខមផេនី** ដែលបានបំរើសេវាកម្មលើផលិតផលភីហ្សា មានការពេញនិយមជាងក្រុមហ៊ុនផ្សេងៗទៀតនៅប្រទេសកម្ពុជា ស្របពេលដែលក្រុមហ៊ុនដែលបំរើសេវាកម្មលើផលិតផលភីហ្សាមានច្រើន។ ដូចនេះខាងក្រោមនេះ ជារចនាសម្ព័ន្ធនៃក្រុមហ៊ុនដែលយកលំនាំអនុវត្តប្រេ្វនឆាយតាមស្តង់ដារ **ក្រុមហ៊ុនដឺភីហ្សាខមផេនី** ដែលមានលក្ខណៈជាសាកល (The Pizza Company World Wide)។

ចំពោះនីតិវិធីសុំសិទ្ធិប្រកបអាជីវកម្ម ជាបឋមខាងក្រុមហ៊ុនដែលជាម្ចាស់ប្រេ្វនឆាយដែលគេហៅថា (Franchiser) ធ្វើការស៊ើបសួរទៅលើការចំណាយមូលធនថា តើក្រុមហ៊ុនដែលជាអ្នកនឹងត្រូវទទួលប្រេ្វនឆាយ (Franchisers) មានច្រើន ឬអត់? មួយវិញទៀតគេធ្វើការសិក្សាទៅលើប្លង់ធុរកិច្ចនៃក្រុមហ៊ុន មានន័យថាសិក្សាទៅលើទីផ្សាស្ថានភាពសេដ្ឋកិច្ច ជីវភាពប្រជាពលរដ្ឋ តំរូវការភីហ្សា និងធ្វើការសិក្សាទៅលើអតិថិជន)។ បន្ថែមពីលើនេះទៀតគឺ ក្រុមហ៊ុនបានធ្វើការចុះសិក្សាដែលជាទំនាក់ទំនងនៃកិច្ចសន្យាប្រេ្វនឆាយ (franchised) ធ្វើការសិក្សាពីគូភាគីទាំងពីរទៅវិញទៅមក ទើបឈានទៅដល់ការព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាប្រេ្វនឆាយឡើង។ ហើយនៅពេលក្លាយជាបណ្តាញប្រេ្វនឆាយហើយ ម្ចាស់ប្រេ្វនឆាយនឹងរៀបចំកិច្ចប្រជុំ ជាមួយអ្នកទទួលប្រេ្វនឆាយប្រចាំឆ្នាំ ហើយកិច្ចសន្យាប្រេ្វនឆាយដែល **ក្រុមហ៊ុនដឺភីហ្សាខមផេនី** បានចុះកិច្ចសន្យាជាមួយ **ក្រុមហ៊ុនម៉ាញន័រហ្វូតគ្រុប** នៅប្រទេសថៃនោះ ត្រូវជាប់ពន្ធចំនួន **១៤ភាគរយ** ជូនរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជានូវចំនួនប្រាក់ចំនេញប្រចាំឆ្នាំលើកិច្ចសន្យាប្រេ្វនឆាយនៅ **ក្រុមហ៊ុន ដឺភីហ្សាខមផេនី** (The Pizza company)។

### ១.១.២. ទីតាំង និងសាខា

**ក្រុមហ៊ុនជីភីហ្សាខមផេនី** មាន១៦សាខាដែលមានដូចជា សាខាផ្សារទំនើបសុរិយា សាខាវិមានទិព្វ សាខាកាល់ម៉ែត្រ សាខាអ៊ែតរ៉ូត សាខាព្រះមុន្នីវង្ស សាខាភីភីអាយយូ សាខាស្ទឹងមានជ័យ សាខាធីខេអាវេនញូទួលគោក សាខាអាកាសយានដ្ឋានភ្នំពេញ សាខាផ្សារទំនើបអ៊ីអន សាខាកម្ពុជាក្រោម សាខាមាត់ទន្លេជិតព្រះបរមព្រះរាជវាំង[៣] និង៤សាខាទៀតនៅតាមខេត្តក្រុងដូចជា ក្រុងសៀមរាប ក្រុងព្រះសីហនុ ក្រុងបាត់ដំបង និងខេត្តកណ្តាលក្រុងតាខ្មៅ[៤]។

### ១.១.៣.ប្រភេទរស់ជាតិ និងសំបកភីហ្សា

នៅ**ក្រុមហ៊ុនជីភីហ្សាខមផេនី** មានបែងចែកជា២៥រស់ជាតិភីហ្សា និងមានសំបក៥ប្រភេទ និងបែងចែកជាទំហំខ្នាតតូច មធ្យម និងខ្នាតធំ។ ចំពោះរស់ជាតិមានដូចជា រស់ជាតិគ្រឿងសមុទ្រ Seafood ខក់ថេល គ្រឿងសមុទ្រ Seafood Cocktail គ្រឿងសមុទ្រត្រូពិច Tropical Seafood ខក់ថេលបង្គា shrimp Cocktail តុំយ៉ាំ គុង Tom Yum Kung បង្គា និងហេម Prawn and Ham បង្គាត្រូពិច Tropical Prawn ស៊ូពើ ឌីឡាកស៍ Super Deluxe ឌីឡាកស៍ Deluxe សាច់ឌីឡាកស៍ Meat Deluxe សាច់មាន់បាប៊ីឃ្យូឌីឡាកស៍ BBQ Chicken Deluxe សាច់ជ្រូកបាប៊ីឃ្យូឌីឡាកស៍ អ៊ីតាលីឌីឡាកស៍ Italian Deluxe បេកខនស៊ូពើឌីឡៃត៍ Bacon Super Delight ផេបផើរ៉ូនីពីរជាន់ Double Pepperoni ហាវៃ Hawaiian សាច់មាន់ទ្រីយ៉ូ Chicken Trio ស្ប៉ៃស៍ប៉ូឡូ Spiced Pollo សាច់មាន់កាលដូ Chicken Cal do បេកខនកាណាដា Canadian Bacon អាឡូហា Aloha ភីហ្សាឈីសពីរជាន់ Double Cheese Pizza ហេម និងផ្សិត Ham and Mushroom វីជី ភីហ្សា Vegetarian។ និងប្រភេទសំបកភីហ្សាមាន៥ប្រភេទដូចជា: សំបកផេន Pan Pizza សំបកស្រួយ Thin Crispy សំបកអ៊ិចស្ត្រាសោះសេជ បៃត៍ ភីហ្សា Extra Cheesy Sausage Bites និងអ៊ិចស្រីម ភីហ្សា Extreme Crust។ ដោយតាមលោក **វ៉ា រដ្ឋមុន្នី** ប្រធានគ្រប់គ្រងផ្នែកទីផ្សារនៅ **ក្រុមហ៊ុនជីភីហ្សាខមផេនី** បានណែនាំពីរស់ជាតិភីហ្សាដែលអតិថិជននិយមចូលចិត្តពិសារ គឺរស់ជាតិគ្រឿងសមុទ្រត្រូពិច ខក់ថេលគ្រឿងសមុទ្រ ហើយសំបកភីហ្សាភាគច្រើនគឺសំបកអ៊ិចស្ត្រាឈីហ្សាសោះសេជ បៃត៍ ភីហ្សា Extra Cheesy Sausage Bites សំបកអ៊ិចស្ទ្រីម ភីហ្សា Extreme Crust និងសំបកផេន ដោយសារតែរស់ជាតិភីហ្សា តំរូវឲ្យផលិតតាមអាស៊ីដែលមានរស់ជាតិមិនប្រៃ និងល្មមបរិភោគ។

[៣] www.efg.com.kh/location_kh.php ចូលមើលថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥

[៤] http://aeonmallphnompenh.com/static/detail/mall The Pizza Company’s Template ចូលមើលថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥

## ១.២. គុណសម្បត្តិ និងគុណវិបត្តិ

### ១.២.១. គុណសម្បត្តិ

ចំពោះ**ក្រុមហ៊ុនដឺភីហ្សាខមផេនី** ដែលទទួលប្រេនឆាយលើម៉ាកពាណិជ្ជនាម ដែលមានកត្តិយសល្បីល្បាញស្រាប់ដែលមានការពេញនិយម រាល់ការអនុវត្តអាជីវកម្មរបស់ក្រុមហ៊ុននីមួយៗនៅតាមបណ្តាប្រទេស ដែលជាអ្នកទទួលប្រេនឆាយត្រូវអនុវត្តតាមស្តង់ដា **ក្រុមហ៊ុនដឺភីហ្សាខមផេនី** ពិភពលោកដែលនៅ **ក្រុមហ៊ុនដឺភីហ្សាខមផេនី** នៅប្រទេសកម្ពុជាមានប្រព័ន្ធស្តុកទុកផលិតផលច្បាស់លាស់ ដែលមានអ្នករៀបចំស្តុកនៅក្នុងឃ្លាំងដែលមានផលិតផលច្រើន សម្រាប់ផ្គត់ផ្គង់ជូនអតិថិជនទៅតាមតំរូវការ ហើយ**ក្រុមហ៊ុនដឺភីហ្សាខមផេនី** ក៏បានប្រេនឆាយបន្តឲ្យទៅ **ក្រុមហ៊ុនសាជីប៉ូលី** នៅសាសាខាព្រលានយន្តហោះអន្តរជាតិភ្នំពេញ។

**ក្រុមហ៊ុន អ៊ិចប្រេះ ហ្វូត គ្រុប (អ៊ី ហ្វេស ជី)** Express Food group (EFG) ជាក្រុមហ៊ុនគ្រប់គ្រងលើ **ក្រុមហ៊ុនដឺភីហ្សាខមផេនី** (The Pizza Company) ដែលទទួលប្រេនឆាយបន្តពី **ក្រុមហ៊ុនម៉ាញន័រ ហ្វូត គ្រុប** (Minor Food Group) មកពីប្រទេសថៃដែលបានផ្តល់សិទ្ធិធ្វើអាជីវកម្មជាលើកដំបូងនៅព្រះរាជាណាចក្រកម្ពុជា។ ការចរាចររបស់**ក្រុមហ៊ុនអ៊ិចប្រេះ ហ្វូត គ្រុប (អ៊ី ហ្វេស ជី)** Express Food Group (EFG) លើផលិតផលភីហ្សាដែលជាក្រុមហ៊ុនផ្តាច់មុខនៅប្រទេសកម្ពុជា។ **ក្រុមហ៊ុនម៉ាញន័រ ហ្វូត គ្រុប** (Minor Food Group) បានបង្កើតស្លាកពាណិជ្ជនាមភីហ្សា និងបើកនៅលើក្រុមហ៊ុនភោជនីយដ្ឋានចំនួន១០០នៅទូទាំងប្រទេសថៃ[៥]។

កំណើនសេដ្ឋកិច្ច និងការខ្វះខាតផលិតផលម៉ាកថ្មី ជាពិសេសនៅក្នុងចំនោមយុវជនដែលបានរួមចំណែកធ្វើឲ្យទីផ្សារ និងការស្វែងរកប្រាក់ចំនេញតាមរយៈអាជីវកម្មនៅប្រទេសកម្ពុជា **ក្រុមហ៊ុនអ៊ី ហ្វេស ជី** (EFG) ជាដែលបានថ្លែងនៅក្នុងវេទិកាស្តីពី សិទ្ធិអាជីវកម្មពិសេសនៅក្នុងរាជធានីភ្នំពេញកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៥ លោក Rami Sharaf អគ្គនាយក **ក្រុមហ៊ុនអ៊ែ អឹម អេ គ្រុប** (RMA Group) បានលើកឡើងថា "នៅរយៈពេលចុងក្រោយនេះ ប្រទេសកម្ពុជាមានស្ថេរភាព និងកំណើនសេដ្ឋកិច្ចដែលបានកើតចេញពីមធ្យោបាយស្វែងរករបៀបនៃការរស់នៅ ដោយសម្លឹងមើលគុណភាពជាចំបង ហើយអាជីវកម្មផ្តាច់មុខបានកើតឡើងនៅឆ្នាំ២០០៥។ ក្រុមហ៊ុន **អ៊ិច ប្រេះ ហ្វូត គ្រុប** Express Food Group (EFG) ដែលជាបងប្អូននឹងក្រុមហ៊ុន RMA Cambodia បាននាំយកប្រេនឆាយលំនាំនៃក្រុមហ៊ុនភីហ្សាមកពីប្រទេសថៃ និងមានការរីកលូតលាស់រហូតមកដល់សព្វថ្ងៃ[៦]។

---

[៥] www.phnompenhpost .com/national/pizza-company-ready-deep-investment ចូលមើលថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥

[៦] www.phnompenhpost.com/business/franchise-industry-expands ចូលមើលថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥

លោក **សុខ ស៊ាង** អ្នកវិភាគផ្នែកហិរញ្ញវត្ថុនៅ **ក្រុមហ៊ុន អ៊ិចប្រេះ ហ្វូត គ្រុប** (**អ៊ី ហ្វេស ជី**) Express Food Group (EFG ) ដែលជាក្រុមហ៊ុនមេគ្រប់ដណ្ដប់លើ **ក្រុមហ៊ុនដឹភីហ្សាខមផេនី** (The Pizza Company) បានផ្ដល់ជាអនុសាស៍ស្ដីពីយុទ្ធសាស្ត្រទីផ្សារថា "ក្រុមហ៊ុន នឹងព្យាយាមពង្រីកឲ្យបានច្រើនសាខា ដែលមានទីតាំងនៅទីប្រជុំជន និងបង្កើនផលិផលថ្មីៗ (Product Innovation) ការអភិវឌ្ឍន៍សេវាកម្មអតិថិជន ហើយក្រុមហ៊ុននឹងបង្កើនការពេញចិត្តចំពោះឥរិយាបថ និងការបង្ហាញរបស់បុគ្គលិកផ្នែកលក់ជូនអតិជន។ មួយវិញទៀត ខាងក្រុមហ៊ុនបានធ្វើការផ្សព្វផ្សាយ (Promotion) ការចូលរួមក្នុងសកម្មភាពសង្គម ដូចជា កីឡាការរត់ប្រណាំងម៉ារ៉ាតុង ខាងស្ថានទូត និងនៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា នាពេលកន្លងជាដើម។ លោកបានបន្ថែមទៀតថា ទាក់ទងទៅនឹងកិច្ចសន្យាហ្វ្រេនឆាយដោយសារតែក្រុមហ៊ុន មានការកែប្រែស្ថានភាពផ្ទៃក្នុងមួយចំនួន និងមានការចងជាកាតព្វកិច្ចនៅក្នុងកិច្ចសន្យាហ្វ្រេនឆាយ ដូចនេះខាងថ្នាក់ដឹកនាំក្រុមហ៊ុនមិនបានអនុញ្ញាត ឲ្យឯកសារកិច្ចសន្យាហ្វ្រេនបង្ហាញជាលក្ខណៈសាធារណៈបានទេ ព្រោះវាស្ថិតនៅចំណុចរក្សាការសម្ងាត់របស់ក្រុមហ៊ុន។ ដោយក្រុមហ៊ុនអាចផ្ដល់ជាលក្ខណៈសំភាសន៍តាមរយៈការបង្ហាញផ្ទាល់ ស្ដីពីកិច្ចសន្យាហ្វ្រេនឆាយ ដោយកាតព្វកិច្ចរបស់ម្ចាស់ហ្វ្រេនឆាយ ត្រូវបង្រៀន ជាលក្ខណៈបណ្ដុះបណ្ដាលទៅកាន់អ្នកទទួលហ្វ្រេនឆាយដូចជា៖ របៀបដំណើរការក្រុមហ៊ុន ការផ្គត់ផ្គង់ទីផ្សារថ្មីៗជាដើម"។

ដោយក្រលេកទៅមើលពីគុណសម្បត្តិនៃកិច្ចសន្យាហ្វ្រេនឆាយនៅ **ក្រុមហ៊ុនដឹភីហ្សាខុមផេនី** តាមជាក់ស្ដែង ក្រុមហ៊ុនទទួលចំណូលសរុប២០លានដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ដោយគិតចាប់ពីពេលចុះកិច្ចសន្យាហ្វ្រេនឆាយលើ **ក្រុមហ៊ុនដឹភីហ្សាខមផេនី** តាំងពីឆ្នាំ២០០៥។ ក៏ប៉ុន្តែតែក្រុមហ៊ុនត្រូវបង់កម្រៃលើសិទ្ធិផ្ដាច់មុខចំនួន**៣៥លាន**ដុល្លាសហរដ្ឋអាមេរិក ដែលជាការបង់កម្រៃដែលមានរយៈពេល**១០ឆ្នាំ** និងធ្វើការទូទាត់ថ្លៃកម្រៃផ្សេងទៀត។ យើងអាចសន្និដ្ឋានបានថា ក្រុមហ៊ុនមានភាគរយនៃប្រាក់ចំនេញច្រើន និងជាកត្តាមួយ ជម្រុញឲ្យមានអគ្រាមានការងារធ្វើ ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជាយើងបានមួយចំនែកផងដែរ។

### ១.២.២. គុណវិបត្តិ

ចំពោះ**ក្រុមហ៊ុនជីភីហ្សាខមផេនី** (The Pizza Company) ក៏នៅមានចំណុចខ្សោយមួយចំនួនដូចជា ក្រុមហ៊ុននៅមិនទាន់មានទិន្នន័យគ្របដណ្តប់នៅទូទាំងប្រទេសនៅឡើយទេ។ ក្រុមហ៊ុនក៏មិនទាន់មានប្រព័ន្ធបច្ចេកវិទ្យាទំនើបៗដូចជាម៉ាស៊ីនផលិត ឬដុតនំទំនើប និងគ្រឿងម៉ាស៊ីនផ្សេងៗនៅឡើយទេ។ ហើយពេលខ្លះក៏មានអតិថិជនបានធ្វើការត្អូញត្អែរចំពោះសេវាកម្ម ដោយហេតុថាមានអតិថិជនមកទទួលសេវាច្រើន ដោយមានការលក់ដាច់ រហូតចំណុចនេះក្លាយជាបញ្ហាក្នុងការបំរើអតិថិជនមិនទាន់ ពីព្រោះតែមានតំរូវការខាងអតិថិជនច្រើន។ នេះសរបញ្ជាក់ឲ្យឃើញថាដើម្បីបំពេញតំរូវការរបស់អតិថិជន **ក្រុមហ៊ុនជីភីហ្សាខមផេនី** ត្រូវបង្កើតហាងភោជនីយដ្ឋាន និងកន្លែងស្តុកទំនិញបន្ថែមទៀតនៅគម្រោងខាងមុខ។

មួយវិញទៀតគឺថា ក្រុមហ៊ុនដែលជាអ្នកទទួលប្រៀនឆាយបន្ត មិនអាចសម្រេចខ្លួនឯងចំពោះការកែប្រែអ្វីមួយ ដោយគ្មានការសម្រេចពីម្ចាស់ប្រៀនឆាយនោះឡើយ។ ឧទាហរណ៍ **ក្រុមហ៊ុនជីភីហ្សាខមផេនី** នៅប្រទេសកម្ពុជាមានគំនិតចង់ប្តូររស់ជាតិភីហ្សាឲ្យទៅជាមានរស់ជាតិផ្អែមបន្តិច ដូចនេះក្រុមហ៊ុនត្រូវសុំសិទ្ធិពីម្ចាស់ប្រៀនឆាយជាដាច់ខាត។

# ជំពូកទី២
# ការបង្កើតកិច្ចសន្យាប្រៀនឆាយ

ជាការពិតណាស់ការបង្កើតកិច្ចសន្យាទូទៅ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈទូទៅនៃកិច្ចសន្យាដែលអាចជាកិច្ចសន្យាទ្វេភាគី ឬកិច្ចសន្យាឯកតោភាគី ដូចនេះរាល់កិច្ចសន្យាទាំងអស់ត្រូវបំពេញលក្ខខណ្ឌនៃកិច្ចសន្យាជាចាំបាច់។ ហើយមុននឹងបង្កើតកិច្ចសន្យាប្រៀនឆាយ ក៏មិនមានលក្ខណៈខុសពីលក្ខណៈនៃកិច្ចសន្យាទូទៅដែរ ពោលគឺត្រូវបំពេញលក្ខខណ្ឌ និងទម្រង់ទៅតាមប្រភេទនៃកិច្ចសន្យា ទើបកិច្ចសន្យាប្រៀនឆាយនោះមានសុពលភាពអនុវត្តបាន។

## ២.១. លក្ខណៈទូទៅនៃកិច្ចសន្យា

ប្រភេទទូទៅនៃកិច្ចសន្យាត្រូវបានបែងចែកជាពីរប្រភេទ គឺប្រភេទនៃកិច្ចសន្យាដែលយកតម្លៃថ្នូរ និងកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ។ កិច្ចសន្យាដែលយកតម្លៃថ្នូរមានន័យថា ជាកិច្ចសន្យាទាំងឡាយណា ដែលគូភាគីទាំងពីរ មានកាតព្វកិច្ចផ្តល់នូវតម្លៃដែលស្មើគ្នាទៅវិញទៅមក។ ឧទាហរណ៍ ដូចជាកិច្ចសន្យាទិញលក់ ភាគីអ្នកលក់មានកាតព្វកិច្ចប្រគល់វត្ថុ រីឯភាគីអ្នកទិញមានកាតព្វកិច្ចប្រគល់ប្រាក់។ ចំនែកឯកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងផ្តល់នូវតម្លៃ រីឯភាគីម្ខាងទៀតមិនមានកាតព្វកិច្ច ឬមានបន្ទុកដែលមិនសមមូល។ ឧទាហរណ៍ដ៏សាមញ្ញនៃកិច្ចសន្យាប្រភេទនេះគឺជាប្រទានកម្ម។ ទាក់ទងទៅនឹងកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ នៅក្នុងករណីប្រទានកម្ម វាមានលក្ខណៈបន្ធូរបន្ថយចំពោះកាតព្វកិច្ចរបស់ទាយក។ ដោយយោងមាត្រា៥៧៤នៃក្រមរដ្ឋប្បវេណី មានន័យថា ជាគោលការណ៍ទាយក មិនចាំបាច់មានបន្ទុក ទទួលខុសត្រូវកាធានាលើវិការៈដែលបានកើតមានឡើងដោយសារកិច្ចសន្យានេះទេ។

ជាទូទៅកិច្ចសន្យាអាចជាកិច្ចសន្យាទ្វេភាគី និងកិច្ចសន្យាឯកតោភាគី។ កិច្ចសន្យាទ្វេភាគីមានន័យថា ភាគីទាំងពីរនៃកិច្ចសន្យាមានកាតព្វកិច្ចអនុវត្តកិច្ចសន្យា ដែលមានតម្លៃសមមូលគ្នា។ រីឯកិច្ចសន្យាឯកតោភាគី សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងមានកាតព្វកិច្ច ចំណែកឯភាគីម្ខាងទៀតមិនមានកាតព្វកិច្ច ឬគ្រាន់តែមានបន្ទុក តែមានតម្លៃមិនសមមូល។ ប្រសិនបើភាគីម្ខាងទៀតមានបន្ទុក ប៉ុន្តែមានតម្លៃមិនសមមូល ក្រមរដ្ឋប្បវេណីបានចែងនូវមាត្រាដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចសន្យាទ្វេភាគីដែរ ដូចជាការទទួលខុសត្រូវ ដាក់ក្នុងការធានារបស់ភាគីអ្នកលក់ ការតវ៉ាឲ្យអនុវត្តព្រមគ្នា ការរំលាយកិច្ចសន្យានៅមាត្រា៥៧៦ នៅកថាខណ្ឌទី២ ទី៣ និងទី៥។

ជាឧទាហរណ៍ **ក** បានធ្វើប្រទានកម្មផ្ទះមួយខ្នងឲ្យទៅ **ខ** ប៉ុន្តែ **ខ** ត្រូវឲ្យកូនរបស់ **ក** រស់នៅលើផ្ទះនេះមួយផ្នែកដែរ។ ក្នុងករណីនេះ **ខ** មានបន្ទុកក្នុងការអនុញ្ញាតឲ្យកូនរបស់ **ក** ប្រើប្រាស់ផ្នែក

មួយនៃផ្ទះនោះ ប៉ុន្តែវាមិនសមមូលទៅនឹងកាតព្វកិច្ចរបស់ **ក**។ ទន្ទឹមនឹងនេះ កិច្ចសន្យាប្រភេទនេះជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ។

លើសពីនេះទៅទៀត នៅក្នុងក្រមរដ្ឋប្បវេណីក៏មានចែងពីកិច្ចសន្យាដែលមានឈ្មោះ ឬកិច្ចសន្យាដែលគ្មានឈ្មោះ។ ចំពោះកិច្ចសន្យាមានឈ្មោះ ឧទាហរណ៍ដូចជា កិច្ចសន្យាលក់ទិញ កិច្ចសន្យាម៉ៅការ កិច្ចសន្យាជួលជាដើម។ ចំណែកឯកិច្ចសន្យាគ្មានឈ្មោះ គឺជាកិច្ចសន្យាដែលមិនមានចែងនៅក្នុងក្រមរដ្ឋប្បវេណីទេ។ កិច្ចសន្យាប្រភេទនេះត្រូវបានបង្កើតឡើងដោយកិច្ចសន្យាជាច្រើនរួមបញ្ចូលគ្នាតែមួយដូចជា ការរួមបញ្ចូលគ្នានៃកិច្ចសន្យាគ្មានឈ្មោះ និងកិច្ចសន្យាមានឈ្មោះ។ ដូច្នេះ គេមិនអាចកំណត់ច្បាស់ពីប្រភេទនៃកិច្ចសន្យានេះទេ។ ឧទាហរណ៍ កិច្ចសន្យារវាងជាងកាត់សំលៀកបំពាក់ និងអតិថិជនដែលបានចែងថា ជាងកាត់សំលៀកបំពាក់ត្រូវផ្តល់នូវក្រណាត់។ យើងអាចមើលឃើញថា កិច្ចសន្យានេះមិនចែងអំពីប្រភេទនៃកិច្ចសន្យាច្បាស់ទេ ព្រោះកិច្ចសន្យានេះកើតឡើងដោយកិច្ចសន្យាពីរបញ្ចូលគ្នាគឺ:

**ក.** កិច្ចសន្យាម៉ៅការ៖ មានន័យថាជាងកាត់សំលៀកបំពាក់ មានកាតព្វកិច្ចសម្រេចការងាររបស់ខ្លួន និងប្រគល់សំលៀកបំពាក់នោះ ចំនែកឯអតិថិជនត្រូវបង់កម្រៃ។

**ខ.** កិច្ចសន្យាលក់ទិញ៖ សំដៅថាអតិថិជនត្រូវបង់ប្រាក់កម្រៃឲ្យទៅអ្នកលក់។

ចំពោះកិច្ចសន្យាទាំងឡាយណា ដែលសំដែងត្រឹមតែជា ការព្រមព្រៀង ដោយយោងតាមមាត្រា៣៣៦ កថាខណ្ឌទី១ ជាទូទៅកិច្ចសន្យាមួយមានសុពលភាព គឺនៅពេលសំណើត្រូវគ្នាជាមួយស្ទីការ។ កិច្ចសន្យាដែលមានសុពលភាពគឺនៅពេលប្រគល់វត្ថុ និងកិច្ចសន្យាជាលក្ខណៈទម្រង់ ដែលសំដៅថា កិច្ចសន្យាដែលមានសុពលភាពត្រូវផ្អែកលើការកំណត់ទម្រង់កិច្ចសន្យាជាក់លាក់។ ឧទាហរណ៍ ការផ្ទេរកម្មសិទ្ធិតាមរយៈកិច្ចសន្យាមានសុពលភាព លុះត្រាតែធ្វើជាលិខិតយថាភូត (មាត្រា៣៣៦ កថាខណ្ឌទី២)[៧]។

### ២.១.១. លក្ខខណ្ឌទូទៅនៃកិច្ចសន្យា

លក្ខខណ្ឌទូទៅដែលទាក់ទងនឹង ភាគីនៃកិច្ចសន្យាត្រូវមានសមត្ថភាពទទួលសិទ្ធិ ជាបុគ្គលមានសមត្ថភាពខាងឆន្ទៈ មានសមត្ថភាពក្នុងការធ្វើសកម្មភាព និងគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ។

លក្ខខណ្ឌទូទៅនៃកិច្ចសន្យា ត្រូវមានប្រភពច្បាស់លាស់ ប្រសិនបើកិច្ចសន្យាមានភាពមិនច្បាស់លាស់ វានឹងនាំឲ្យមោឃភាព ព្រោះថាខ្លឹមសារនៃកាតព្វកិច្ចក្នុងកិច្ចសន្យា មិនអាចយកទៅអនុវត្តបានតាមរយៈតុលាការ។ ជាឧទាហរណ៍ **ក** បានសន្យាថា បើ **ខ** គ្រប់អាយុ១៨ឆ្នាំ **ក** នឹងឲ្យ

[៧]សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១ បោះពុម្ពទី១ ខែមេសា ឆ្នាំ២០១៣, ទំព័រ ១០១

អ្វីៗដែលល្អដល់ ខ។ ចំពោះខ្លឹមសារនៃការសន្យាបែបនេះ តុលាការមិនអាចចេញសាលក្រម ឬមិនអាចអនុវត្តកាតព្វកិច្ចដោយបង្ខំបានទេ ដោយហេតុថាខ្លឹមសារនៃកិច្ចសន្យាមានភាពមិនច្បាស់លាស់។ ក៏ប៉ុន្តែវាក៏មិនមានភាពចាំបាច់ ក្នុងការសម្រេចថា រាល់ខ្លឹមសារទាំងអស់នៅក្នុងកិច្ចសន្យាត្រូវតែមានភាពច្បាស់លាស់នោះទេ។ វាមានលក្ខណៈគ្រប់គ្រាន់ ដែលបង្ហាញពីភាពច្បាស់លាស់ ប្រសិនបើផ្នែកសំខាន់នៃកិច្ចសន្យាអាចត្រូវបានបង្ហាញ ឲ្យឃើញច្បាស់តាមរយៈការបកស្រាយ។

ឧទាហរណ៍ កិច្ចសន្យាលក់ទិញរវាង **ក** និង **ខ** មិនបានកំណត់ថ្លៃ។ កិច្ចសន្យាមិនត្រូវបានចាត់ទុកជាមោឃៈជាចាំបាច់នោះទេ ប្រសិនបើពួកគាត់បានព្រមព្រៀងគ្នា ពីវិធីកំណត់ថ្លៃទិញនៅពេលអានាគត់ (មាត្រា៥២១)។ ឬនិយាយម្យ៉ាងទៀត ភាគីអាចកំណត់ប្រាក់ថ្លៃទិញ នៅពេលអនុវត្តកិច្ចសន្យាក៏បាន មិនមែនចាំបាច់តែនៅពេលបង្កើតកិច្ចសន្យាទេ។ ប្រសិនបើមានការព្រមព្រៀងគ្នាពីវិធីកំណត់ថ្លៃទិញ ប៉ុន្តែភាគីមិនអាចមានការឯកភាពលើតម្លៃលក់ទិញ នោះភាគីអាចប្ដឹងទៅតុលាការបាន។ តុលាការត្រូវសម្រេចពីប្រាក់ថ្លៃលក់ទិញ ដោយធ្វើការពិចារណាទៅលើឆន្ទៈពិតប្រាកដរបស់ភាគី តម្លៃនៅលើទីផ្សារ ឬទំនៀមទម្លាប់នៃកិច្ចការជំនួញជាដើម។

យោងតាមមាត្រា៣៥៤ កថាខណ្ឌទី១ ចំណុចក ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ នោះវានឹងត្រូវបានចាត់ទុកជាមោឃៈ។ បញ្ញត្តិដែលអនុវត្តដោយបង្ខំអាចបដិសេធរាល់អានុភាពនៃសកម្មភាពគតិយុត្តដែលបានធ្វើឡើងផ្ទុយនឹងបញ្ញត្តិនេះ។

ឧទាហរណ៍ នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាថា "ភាគីម្ខាងមិនអាចលុបកិច្ចសន្យាបានទេ ទោះបីជាគាត់បង្ហាញឆន្ទៈ ដោយសារការគំរាមគំហែងក៏ដោយ" ការព្រមព្រៀងបែបនេះត្រូវចាត់ទុកជាមោឃៈព្រោះវាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ។

លក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា៣៥៤ កថាខណ្ឌទី១ ចំណុចខ នៃក្រមរដ្ឋប្បវេណីមានចែងពីភាពសមស្របតាមស្ថានភាពសង្គមដែលមានន័យថា ទោះបីជាគូភាគីបង្ហាញឆន្ទៈដោយមានវិការៈក៏ដោយ ក៏កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈដែរ ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាផ្ទុយពីស្ថានភាពសង្គម និងទំនៀមទំម្លាប់ល្អជាដើម។

ការបង្ហាញឆន្ទៈមិនពិត ឧទាហរណ៍ **ក** លក់ដីឲ្យ **ខ** ដោយខុបឃិតគ្នានៅក្នុងគោលបំណងបញ្ចៀសពីការរឹបអូសពីម្ចាស់បំណុល។ បន្ទាប់មក **ក** បានផ្ទេរការចុះបញ្ជីនៃដីទៅឲ្យ **ខ** នេះជាការបង្ហាញឆន្ទៈមិនពិត កិច្ចសន្យារវាង **ក** និង **ខ** ត្រូវបានចាត់ទុកជាមោឃៈ (មាត្រា៣៥៣)[៤]។

[៤] សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណីភាគ១, ទំព័រ១០៣ និងទំព័រ១០៤

យោងតាមមាត្រា៣៣៨ នៃក្រមរដ្ឋប្បវេណីដែលចែងអំពីសំណើដែលមាន ឬគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ។

**ក. សំណើដែលកំណត់អំឡុងពេលសម្រាប់ស្វីការ**

សំណើអាចភ្ជាប់ជាមួយនឹងរយៈពេលសម្រាប់ស្វីការ។ ប្រសិនបើ វាមិនមានភាពច្បាស់លាស់ថា តើអ្នកបានកំណត់ថ្ងៃណាមួយនោះទេ នោះវាត្រូវគិតពីថ្ងៃដែលសំណើត្រូវបានផ្ញើរចេញ។ សំណើត្រូវបានធ្វើដើម្បីជាប្រយោជន៍របស់អ្នកស្នើខ្លួនឯងផ្ទាល់ ព្រោះអ្នកស្នើអាចធ្វើសំណើនេះទៅបុគ្គលផ្សេងទៀតបាន ប្រសិនបើគាត់មិនបានទទួលស្វីការនៅក្នុងអំឡុងពេលនោះ។ អ្នកស្នើមិនចាំបាច់ដកសំណើរបស់ខ្លួននៅក្រោយអំឡុងពេលសម្រាប់ស្វីការទេ។ ការកំណត់អំឡុងពេលនេះគឺដើម្បីបញ្ជាក់ពីឆន្ទៈរបស់អ្នកស្នើ ក្នុងការរងចាំអំឡុងពេលសម្រាប់ស្វីការ ហើយប្រសិនបើអ្នកធ្វើសំណើ ភាគីចង់ដកយកសំណើវិញ អ្នកទទួលសំណើអាចទទួលរងការខូចខាតដែលមិនអាចរំពឹងទុកជាមុនបាន។ ដូចនេះក្នុងករណីនេះ អ្នកដាក់សំណើមិនអាចដកសំណើបានទេ ប៉ុន្តែប្រសិនបើមិនមានការឆ្លើយតប ឬក៏អ្នកស្វីការធ្វើការបដិសេដចំពោះសំណើនោះ ក្នុងអំឡុងពេលកំណត់ទេ សំណើនោះនឹងត្រូវបាត់បង់អានុភាព។

**ខ.សំណើដែលមិនកំណត់អំឡុងពេលសម្រាប់ស្វីការ**

ប្រសិនបើគូភាគីកំពុងនិយាយចរចារគ្នា ឧទាហរណ៍ដូចជា ភាគីកំពុងតែនិយាយទល់មុខគ្នា ឬនិយាយតាមទូរស័ព្ទ ហើយបើភាគីដែលទទួលសំណើមិនបានឆ្លើយតបភ្លាមៗ ហើយមិនផ្តល់ស្វីការទេ នាំឲ្យសំណើនោះមិនមានអានុភាព។ ឧទាហរណ៍ **ក** បានផ្តល់សំណើលក់ប៊ិចធម្មតាឲ្យទៅ **ខ** នៅពេលដែលកំពុងនិយាយគ្នា។ ប្រសិនបើ **ខ** មិនបានឆ្លើយតបភ្លាមៗនោះទេ សំណើរនោះត្រូវបាត់បង់អានុភាព។

អំឡុងពេលសមរម្យ គឺជាការបកស្រាយតាមស្ថានភាពជាក់ស្តែង ចំពោះខ្លឹមសារនៃកិច្ចសន្យា និងទំហំនៃវត្ថុជាដើម។

**២.១.២. ការព្រមព្រៀង**

ការព្រមព្រៀងក្នុងន័យកិច្ចសន្យា ដើម្បីបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យាបាន លុះត្រាតែកិច្ចសន្យានោះត្រូវបានធ្វើឡើងដោយសំណើ និងស្វីការ។ និយមន័យនៃសំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើង ដោយមានឆន្ទៈចងភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើរនេះ។ សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានទៅដល់ភាគីម្នាក់ទៀត។ ប៉ុន្តែប្រសិនបើដំណឹងនៃការដកយកសំណើវិញដល់ភាគីម្ខាងទៀតនៅពេលព្រមគ្នានឹងពេលសំណើបានដល់ ឬមុនពេលសំណើដល់ នោះអានុភាពនៃស្វីការមិនត្រូវ

កើតឡើយ[៩]។ ហើយកិច្ចសន្យាដែលមានអានុភាពអនុវត្តបាន លុះត្រាតែកិច្ចសន្យាដែលធ្វើជាលិខិតយថាភូត[១០]។

ជាទូទៅកិច្ចសន្យាដែលត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរបស់គូភាគី មានកម្មវត្ថុស្របច្បាប់ ហើយធ្វើឡើងដោយសមត្ថជន នោះកិច្ចសន្យានឹងមានអានុភាពអនុវត្ត។ ប៉ុន្តែនៅក្នុងករណីមួយចំនួន កិច្ចសន្យាដែលបំពេញគ្រប់លក្ខខណ្ឌខាងលើ នៅតែត្រូវបានគេលុបចោលដោយសារមានវិការៈតាមរូបភាពមួយចំនួនដូចជា ការភាន់ច្រឡំ ការឆបោក ឬការគំរាមគំហែង និងកិច្ចសន្យាដែលកើតពីអំពើកេងយកចំណេញហួសហេតុជាដើម[១១]។ សកម្មភាពដែលមានវិការៈទាំងនេះត្រូវបានគេហៅថា សកម្មភាពដែលអាចលុបចោលបាន។

ក្រមរដ្ឋប្បវេណី ក៏បានបញ្ញត្តិអំពី បបមនីយផ្លូវចិត្ត និងការបង្ហាញឆន្ទៈមិនពិតផងដែរ។ នៅក្នុងករណីដែលការបង្ហាញឆន្ទៈមិនពិត និងបបមនីយផ្លូវចិត្ត ការបង្ហាញឆន្ទៈគឺអាចនិយាយបានថាមានវិការៈ ព្រោះវាមិនឆ្លុះបញ្ចាំងពីឆន្ទៈពិតប្រាកដ។ ជាការពិតអ្នកបង្ហាញឆន្ទៈគឺអាចលើកឡើងថាការបង្ហាញឆន្ទៈរបស់ខ្លួន គឺមានវិការៈ និងត្រូវបានទុកជាមោឃៈ ព្រោះភាគីបានដឹងថា វាមិនមែនជាឆន្ទៈរបស់ខ្លួននោះ ជាគោលការណ៍ ភាគីមិនអាចលើកឡើងពីសន្យាមិនពិត នោះពួកគេមិនអាចអះអាងពីសុពលភាពនៃកិច្ចសន្យាបានទេ[១២]។

### ២.១.៣. សមត្ថភាព

តាមស្ថានភាពដែលអាចជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច គ្រប់បុគ្គលទាំងអស់ត្រូវតែទទួលបាននូវសិទ្ធិដោយគ្មានករណីលើកលែង។ សិទ្ធិដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីមានច្រើនដូចជា សិទ្ធិក្នុងការបង្កើតកិច្ចសន្យា សិទ្ធិទទួលបានមរតក សិទ្ធិទាមទារសំណងខូចខាតជាដើម។ ជាគោលការណ៍ គ្រប់រូបវន្តបុគ្គលទាំងអស់ មិនថាជនជាតិខ្មែរ ឬជនជាតិបរទេសអាចទទួលបាននូវសិទ្ធិបុគ្គលដូចគ្នា។ ប៉ុន្តែចំពោះជនបរទេសមិនអាចទទួលបាន ឬកាន់កាប់សិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ នៅក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។ ការកម្រិតសិទ្ធិនេះ ក៏មានចែងនៅក្នុងបញ្ញត្តិនៃមាត្រា៤៤ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ

---

[៩] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៣៣៧

[១០] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៣៣៦

[១១] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៣៤៥

[១២] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១, ទំព័រ១២០

ព្រះរាជាណាចក្រកម្ពុជាផងដែរ។ បញ្ញត្តិនេះបានចែងថា មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។

នៅផ្នែកទី១ នៅគន្លឹទី២ បានចែងអំពីសមត្ថភាពទទួលសិទ្ធិ ហើយរូបវន្តបុគ្គលម្នាក់ៗមានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់សមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព[១៣]។ ចំពោះអត្ថន័យនៃកំណើត និងមរណភាព ក្រមរដ្ឋប្បវេណីមិនមានចែងទេ ហើយវាត្រូវបើកចំហរឲ្យធ្វើការបកស្រាយ តាមការអនុវត្តនៅកម្ពុជា។ សម្រាប់ជាការយោងនៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន កំណើតគឺជាពេលដែលខ្លួនទារកទាំងមូលបានចេញផុតពីគភ៌ម្តាយ ហើយមានជីវិត។ រីឯមរណភាព គឺជាពេលដែលសួត បេះដូង ខួរក្បាល ឈប់មានដំណើរការ ហើយមានគេបញ្ជាក់មរណភាព ដោយពិនិត្យមើលការអស់ដង្ហើម បេះដូងឈប់លោត និងការរីកនៃប្រស្រីភ្នែក ព្រមទាំងភាពគ្មានប្រតិកម្មនៃពន្លឺ។

សមត្ថភាពខាងឆន្ទៈ គឺសំដៅលើសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ សកម្មភាពនៅពេលនេះមានន័យថា ជាកិច្ចសន្យា និងសកម្មភាពឯកតោភាគី។ គោលការណ៍ស្វ័យភាពបុគ្គលឯកជន បុគ្គលអាចបង្កើតទំនាក់ទំនងគតិយុត្តរបស់ខ្លួនដោយត្រឹមត្រូវ។ ការចែងពីសមត្ថភាពខាងឆន្ទៈ និងវិធីសម្រាប់ការពារកុំឲ្យមានការខូចខាតដល់កិច្ចការជំនួញរបស់អ្នកដែលពុំមានសមត្ថភាពគ្រប់គ្រាន់ នៅក្នុងការយល់ដឹង និងការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។

មានន័យថា សមត្ថភាពនៃកិច្ចសន្យាសំដៅទៅលើសមត្ថភាព ដែលកើតចេញពីសកម្មភាពរបស់នីតិជន ឬជនគ្រប់អាយុនៃច្បាប់កំណត់ ដោយជៀសវាងបុគ្គលដែលត្រូវបានគេកំណត់សិទ្ធិ ឬជនខ្វះសមត្ថភាពខាងឆន្ទៈ មានន័យថា ជាសកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន[១៤]។ ហើយសម្រាប់សកម្មភាពណា ដែលបានធ្វើដោយជនដែលស្ថិតនៅក្រោមស្ថានភាពចុះថយយ៉ាងខ្លាំង នូវសមត្ថភាពយល់ដឹង និងការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ សកម្មភាពរបស់ជននោះត្រូវបានលុបចោលបាន។ ឧទាហរណ៍ បុគ្គលដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបាននូវសកម្មភាពរបស់ខ្លួន ដោយសារជននោះបរិភោគស្រាច្រើនរហូតស្រវឹង ឬជននោះប្រើប្រាស់ថ្នាំ ដែលប៉ះពាល់ដល់សមត្ថភាពខាងឆន្ទៈ។ ប្រសិនបើសាមីជន ឬសន្តតិជន ឬអច្ច័យលាភី លុបចោលសកម្មភាពនោះ ត្រូវចាត់ទុកជា

[១៣] មាត្រា៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[១៤] មាត្រា១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

មោឃៈតាំងពីដំបូង។ ចំនែកឯការកំណត់សមត្ថភាពក្នុងការធ្វើសកម្មភាព ត្រូវបានកំណត់ចំពោះជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ហើយជនដែលត្រូវបាន កម្រិតសមត្ថភាពសំដៅទៅលើជនដូចជា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ[១៥]។

ផ្នែកទី៤ នៅក្នុងគន្ថីទី២ នៃក្រមរដ្ឋប្បវេណីបានចែងអំពីរបបសមត្ថភាពក្នុងការធ្វើសកម្មភាពដែលមានគោលបំណង ដើម្បីការពារកុំឲ្យមានការខូចខាតដែលកើតឡើងដោយសារកិច្ចការជំនួញរបស់អ្នកដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាព។ ទោះបីជាបុគ្គលដែលមិនមានសមត្ថភាពក្នុងការធ្វើសកម្មភាពនាពេលធ្វើសកម្មភាពនោះ វាមានការលំបាកក្នុងការបញ្ជាក់ពីសមត្ថភាពនេះនៅពេលក្រោយ។ ជាលទ្ធផល វាមានភាពចាំបាច់ណាស់ក្នុងការចាត់ចំណាត់ថ្នាក់បុគ្គលដែលមិនមានសមត្ថភាពខាងឆន្ទៈ និងកម្រិតនូវសមត្ថភាពរបស់ពួកគាត់ក្នុងការធ្វើសកម្មភាពដើម្បីការពារសិទ្ធិរបស់ពួកគាត់ និងរក្សានូវស្ថិរភាពប្រត្តិបត្តិការនៃជំនួញ។

អនីតិជនដែលត្រូវបានអនុញ្ញាតឲ្យប្រកបអាជីវកម្មមួយប្រភេទ ឬច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជនចំពោះមុខជំនួញនោះ[១៦]។ និយាយម្យ៉ាងទៀតមានន័យថា សមត្ថភាពក្នុងការធ្វើសកម្មភាពសំដៅថាសមត្ថភាពដែលបុគ្គលម្នាក់អាចបង្ហាញឆន្ទៈប្រកបដោយប្រសិទ្ធភាពជាស្ថាពរ និងដោយឯករាជ្យ។ តាមន័យនេះបុគ្គលដែលមានសកម្មភាពពេញលេញ អាចបង្ហាញឆន្ទៈប្រកបដោយសុពលភាព ដោយការសម្រេចចិត្តរបស់ខ្លួនផ្ទាល់ ដោយមិនចាំបាច់មានជំនួយពីបុគ្គលណាម្នាក់ឡើយ។

### ២.១.៤. កម្មវត្ថុ

កម្មវត្ថុនៃកិច្ចសន្យាសំដៅទៅលើ គោលបំណងចំបងដែលគូភាគីនៃកិច្ចសន្យាបានកំណត់ទុកនៅក្នុងកិច្ចសន្យា។

ប្រភេទនៃកាតព្វកិច្ចដែលមានគោលបំណងផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លើវត្ថុ ឬប្រាក់ កាតព្វកិច្ចអាចមានគោលបំណងឲ្យអនុវត្ត និងមិនឲ្យអនុវត្តសកម្មភាពណាមួយបាន[១៧]។ ចំពោះក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ត្រូវកំណត់ដោយប្រភេទនៃវត្ថុ ប្រសិនបើកម្មវត្ថុដែលត្រូវផ្តល់មានគុណភាពច្រើនយ៉ាង កូនបំណុលមានកាតព្វកិច្ចផ្តល់វត្ថុដែលមានគុណភាពដូចដែលភាគីបានកំណត់។ នៅក្នុងករណីដែលគូភាគីមិនបានកំណត់ពីប្រភេទគុណភាព កូនបំណុលមានករណីកិច្ចផ្តល់

[១៥] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[១៦] មាត្រា២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[១៧] មាត្រា៣១៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា

វត្ថុដែលមានគុណភាពមធ្យម។ កាតព្វកិច្ចដែលបានកំណត់ប្រភេទ ក្រោយពេលដែលកូនបំណុលបានកំណត់កម្មវត្ថុដែលបានត្រូវផ្តល់ច្បាស់លាស់ និងបានបញ្ចប់សកម្មភាពចាំបាច់ ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់នោះ កូនបំណុលមានកាតព្វកិច្ចផ្តល់វត្ថុតែប៉ុណ្ណោះ[១៨]។

ក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាជាសាច់ប្រាក់ កូនបំណុលអាចសងជារូបិយវត្ថុផ្សេងៗ តាមការជ្រើសរើសរបស់ខ្លួន។ ប៉ុន្តែម្ចាស់បំណុល និងកូនបំណុលអាចកំណត់ការសងជាកម្មវត្ថុពិសេសក្រៅពីសាច់ប្រាក់បាន[១៩]។

### ២.១.៥. មូលហេតុ

មូលហេតុនៃការរលត់កាតព្វកិច្ចមានដូចជា៖

**ក.** ការសង ការទូទាត់ ការលើកលែង នវកម្ម ឬព្យាកុភាព

**ខ.** អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ដោយគ្មានកំហុសរបស់ភាគីកូនបំណុល

**គ.** ការបំពេញលក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ឬការរំលាយកិច្ចសន្យា

**ឃ.** ការផុតអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល

**ង.** ការអនុវត្តសិទ្ធិលុបចោល។

**ច.** ការយឺតយ៉ាងក្នុងការទទួល

ក្នុងករណីដែលសំណើផ្តល់ការសងមិនត្រូវបានទទួល ឬស្ទីការមិនទទួលចំពោះសំណើ ដែលបណ្តាលមកពី (កំហុសដោយចេតនា ឬកំហុសដោយអចេតនា) របស់ម្ចាស់បំណុលនៅពេលជាមួយគ្នានេះ កូនបំណុលអាចទាមទារឲ្យម្ចាស់បំណុល សងសំណងការខូចខាតចំពោះសោហ៊ុយ ដូចជាសោហ៊ុយសម្រាប់រក្សាទុកវត្ថុ ដែលជាកម្មវត្ថុនៃការសងក្នុងឃ្លាំងដែលកូនបំណុលបានចំណាយដើម្បីរក្សាទុកនោះក្នុងរយៈពេលដ៏វែង ដោយសារមូលហេតុថា ម្ចាស់បំណុលមិនទទួលសង ឬចំពោះពន្ធផ្សេងៗលើអចលវត្ថុជាអាទិ៍ (យោងតាមមាត្រា៤៥៦ កថាខណ្ឌទី២)។ លើសពីនេះទៅទៀត ក្នុងករណីនៃការមិនទទួលសំណើរផ្តល់ការសងរបស់ម្ចាស់បំណុល គឺជាការបំពានករណីកិច្ចយ៉ាងធ្ងន់ធ្ងរ ភាគីម្ខាងទៀតនៃកិច្ចសន្យាអាចរំលាយកិច្ចសន្យាបានភ្លាមៗ។ ការរំលាយកិច្ចសន្យា គឺធ្វើបានតែចំពោះកិច្ចសន្យាអញ្ញមញ្ញតែប៉ុណ្ណោះ ពីព្រោះការរំលាយកិច្ចសន្យា នាំឲ្យភាគីទាំងសងខាងនៃកិច្ចសន្យាអញ្ញមញ្ញ សំដៅថា ភាគីម្ខាងឆ្លៀតឱកាសរំលោភលើស្ថានភាព នៅពេលភាគីម្ខាងទៀតកំពុងជួបប្រទេះនូវការលំបាកផ្នែកសេដ្ឋកិច្ច ឬសង្គម ឬភាពមិនត្រឹមត្រូវតាមស្ថានភាពដទៃទៀត

[១៨] មាត្រា៣១៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា

[១៩] មាត្រា៣១៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា

ដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបាន តាមមាត្រា៤០៧នៃក្រមរដ្ឋប្បវេណី។ ហើយបើមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរ នោះគ្មានសង្ឃឹមថាភាគីម្ខាងទៀតនឹងអនុវត្តកាតព្វកិច្ចរបស់ខ្លួនមកធ្វើជាមូលហេតុឡើយ។ ហើយចំពោះភាគីរងការរំលោភបំពាន ត្រូវធ្វើការដាស់តឿនភាគីម្ខាងទៀត ឲ្យអនុវត្តកាតព្វកិច្ច ប្រសិនបើភាគីនោះនៅតែមិនអនុវត្តកាតព្វកិច្ច ទោះបីជាមានការដាស់តឿនក៏ដោយ។ ចំណុចនេះនៅពេលដែលភាគី បានកំណត់នៅក្នុងកិច្ចសន្យា តែភាគីមិនបានអនុវត្តតាមពេលវេលាកំណត់នៃកិច្ចសន្យានោះ។

## ២.២. លក្ខខណ្ឌពិសេសនៃកិច្ចសន្យាប្រេ្វនឆាយ

ចំពោះលក្ខខណ្ឌពិសេសនៃកិច្ចសន្យាប្រេ្វនឆាយមានន័យថា គឺជាដំណាក់កាលនីមួយៗនៃកិច្ចសន្យាប្រេ្វនឆាយដែលមានដូចជា ការស្វែងរកអ្នកទទួលប្រេ្វនឆាយ ដំណាក់កាលនៃកិច្ចសន្យាបឋម លក្ខខណ្ឌអប្បរមាសំខាន់ៗ លក្ខខណ្ឌសុពលនៃកិច្ចសន្យា លក្ខខណ្ឌដែលអាចតតាំងនឹងតតិយជន និងរយៈពេលនៃកិច្ចសន្យា។

### ២.២.១. ការប្រកាសស្វែងរកអ្នកទទួលប្រេ្វនឆាយ

នៅក្នុងសេចក្តីព្រាងស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ការប្រកាសស្វែងរកអ្នកទទួលប្រេ្វនឆាយមាននៅមាត្រា៩៨ ដែលការស្វែងរកអ្នកទទួលប្រេ្វនឆាយ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចជា៖ ការប្រកាសស្វែងរកអ្នកទទួលប្រេ្វនឆាយ ត្រូវតែមានលក្ខណៈច្បាស់លាស់ហើយជាក់លាក់ ដែលជាចំណុចមិននាំឲ្យមានការយល់ច្រឡំ។ ហើយការផ្សព្វផ្សាយដើម្បីជ្រើសរើសទៀតសោត ត្រូវតែមានអំណះអំណាងអំពីលទ្ធផល ដែលអាចទទួលបានក្នុងពេលអានាគត់ ឬបញ្ជាក់អំពីផលនៃចំណូលដែលរំពឹងទុកដោយអ្នកទទួលប្រេ្វនឆាយ ហើយត្រូវមានលក្ខណៈជាសត្យានុម័ត[២០]។

ដូចនេះទេចំពោះការប្រកាសស្វែងរកអ្នកទទួលប្រេ្វនឆាយនេះ ចាំបាច់ណាស់ក្នុងការបង្ហាញពីគោលបំណងជាក់លាក់ និងច្បាស់លាស់ដែលមិនបណ្តាលឲ្យបេក្ខភាពមានមន្ទិលសង្ស័យ ដែលជាហេតុអវិជ្ជមាន ក្នុងការបោះបង់ចោលការចាប់អារម្មណ៍ពីការទិញសិទ្ធិពីម្ចាស់ប្រេ្វនឆាយ ដូចដែលនៅក្នុងក្រមរដ្ឋប្បវេណី បានចែងផងដែរពីវិការៈនៃការព្រមព្រៀង និងឈានទៅដល់ការបង្កើតកិច្ចសន្យាមួយដែលមានវិការៈ ដែលនាំឲ្យមានការមោឃភាពកិច្ចសន្យានោះទុកជាមិនបានការ។ ហេតុដូចនេះ ដើម្បីជៀសវាងការខាត់បង់ពេលវេលា និងថវិកា ការប្រកាសស្វែងរកអ្នកទទួលប្រេ្វនឆាយជារឿងមួយដែលគួយកចិត្តទុកដាក់ ជៀសវាងមានហានិភ័យណាមួយកើតឡើងដែលបណ្តាលឲ្យ

[២០] សេចក្តីព្រាងស្តីពីកិច្ចសន្យាពាណិជ្ជកម្មឆ្នាំ២០១១, មាត្រា៩៨

ខូចផលប្រយោជន៍[២១]។ ដូចនេះការប្រកាសស្វែងរកអ្នកទទួលប្រេីនឆាយ ត្រូវបង្ហាញឲ្យបានច្បាស់អំពីផលប្រយោជន៍ ក្រោយពីពេលទទួលសិទ្ធិប្រេីនឆាយបន្តពីខ្លួនដូចជា នឹងទទួលបានផលចំណូលយ៉ាងណាខ្លះជាដើម។

អានុភាពនៃការប្រកាសស្វែងរកអ្នកទទួលប្រេីនឆាយសំដៅថា បេក្ខភាពដែលត្រូវបានជ្រើសរើសដោយម្ចាស់ប្រេីនឆាយ ដែលនិយាយឲ្យចំគេហៅថា អ្នកអនុវត្តអាជីវកម្មជាមួយគ្នា។ នេះហើយជាជំហានបន្ទាប់នៃការបង្កើតកិច្ចសន្យាបឋមរវាងម្ចាស់ប្រេីនឆាយ និងអ្នកទទួលប្រេីនឆាយ មុន នឹងឈានទៅដល់ដំណាក់នៃការបង្កើតកិច្ចសន្យាប្រេីនឆាយ លើផលិតផលរបស់ខ្លួនជាស្ថាពរ។

ចំពោះការអនុវត្តកិច្ចសន្យាប្រេីនឆាយនៅ **ក្រុមហ៊ុនដឹភីហ្សាខមផេនី**(The Pizza Company) លោក **វ៉ា រដ្ឋមុន្នី** អ្នកគ្រប់គ្រងផ្នែកទីផ្សារ តាមរយៈការសំភាសន៍ផ្ទាល់ លោកបានរៀបរាប់ពីការប្រកាសស្វែងរកអ្នកទទួលប្រេីនឆាយថា "រវាងភាគីក្រុមហ៊ុននៅប្រទេសកម្ពុជា និងភាគីនៅប្រទេសថៃគឺក្រុមហ៊ុន **ម៉ាញន័រហ្វូតគ្រុប** (Minor Food Group) ដែលជាក្រុមហ៊ុនម្ចាស់ប្រេីនឆាយរបស់ **ក្រុមហ៊ុនដឹភីហ្សាខមផេនី** នៅប្រទេសកម្ពុជា។ នៅដំណាក់កាលនោះផងដែរ គឺជាចំណុចដំបូងនៃការករកើតនូវទំនាក់ទំនងប្រេីនឆាយ ហើយក្រុមហ៊ុនត្រូវពិនិត្យស្តង់ដាភោជនីយដ្ឋានជាមុនសិន ដោយឆ្លងឆ្លើយរវាងក្រុមហ៊ុនទាំងពីរ។ មានន័យថាដំបូងក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា ត្រូវស្វែងរកទីតាំងទីប្រជុំជនសម្រាប់ការបើកហាង ដោយឆ្លងកាត់ការពិនិត្យវាយតម្លៃពីគណៈគ្រប់គ្រងជាន់ខ្ពស់ និងអ្នកជំនាញ ហើយចាប់ផ្តើមធ្វើទំនាក់ទំនងទៅភាគីម្ចាស់ប្រេីនឆាយនៅប្រទេសថៃ រហូតឈានដល់ការជួបផ្ទាល់រវាងក្រុមហ៊ុន ដែលជាអ្នកទទួលប្រេីនឆាយ និងភាគីនៅប្រទេសថៃតាមរយៈការចរចារទំនាក់ទំនងតាមទូរស័ព្ទ ឬអ៊ីម៉ែល ដោយឆ្លងកាត់ការផ្តល់ព័ត៌មានសំខាន់ៗមួយចំនួនដូចជា អត្តសញ្ញាណនៃក្រុមហ៊ុនម្ចាស់ប្រេីនឆាយ តម្លៃ និងរយៈពេលកិច្ចសន្យាប្រេីនឆាយដែលពាក់ព័ន្ធ រហូតឈានដល់ដំណាក់កាលជួបមើលស្ថានភាពជាក់ស្តែងនៅភាគីក្រុមហ៊ុនទាំងពីរ"។

### ២.២.២. កិច្ចសន្យាបឋម

កិច្ចសន្យាបឋមដែលមានចែងនៅក្នុងសេចក្តីព្រាងស្តីពីកិច្ចសន្យាពាណិជ្ជកម្ម បានកំណត់ពីកិច្ចសន្យាបឋម គឺជាកិច្ចសន្យាដែលបានបង្កើតឡើងរវាងម្ចាស់ប្រេីនឆាយ និងអ្នកដែលមានបំណងទទួលប្រេីនឆាយ ដើម្បីរៀបចំទំនាក់ទំនងសម្រាប់ពេលអានាគត់ ប៉ុន្តែមិនមានន័យថាជាកិច្ចសន្យាប្រេីនឆាយទេ។

ដើម្បីអនុញ្ញាតឲ្យអ្នកមានបំណងទទួលប្រេីនឆាយមានការយល់ដឹងពេញលេញ ម្ចាស់ប្រេីនឆាយ ត្រូវផ្តល់ឯកសារជាព័ត៌មានទាំងអស់អំពីទំនាក់ទំនងប្រេីនឆាយឲ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវជាលាយលក្ខណ៍អក្សរទៅឲ្យអ្នកមានបំណងចង់ទទួលប្រេីនឆាយ ក្នុងរយៈពេលមួយសម

[២១] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា, មាត្រា១៤

ស្របមុននឹងចុះកិច្ចព្រមព្រៀងប្រេ្វនឆាយ។ ហើយកិច្ចសន្យាបឋមនោះត្រូវមានលក្ខខណ្ឌសំខាន់ៗ ដូចជា៖

